ការអង្កេតលម្អិតនេះ នឹងចាប់ផ្តើមបន្ទាប់ពីការគូសប្លង់នៃថ្នល់រួចរាល់ និងមានការកំណត់របៀងនៃផលប៉ះពាល់រួចជាស្រេចនៅទីតាំងជាក់ស្តែង។ សកម្មភាពនេះ នឹងអនុវត្តពេលមានវត្តមាននៃគ្រួសារប៉ះពាល់។ គ្រួសារដែលរងផលប៉ះពាល់ និងអាជ្ញាធរមូលដ្ឋាននឹងត្រូវបានជូនដំណឹងមុននឹងអនុវត្តការងារនេះ។

## តើគម្រោងនឹងផ្តល់ព័ត៌មាន និងពិគ្រោះជាមួយខ្ញុំយ៉ាងដូចម្តេច?

គម្រោងនឹងជូនដំណឹងដល់អាជ្ញាធរមូលដ្ឋានអំពីសកម្មភាពនានា។ ព័ត៌មាននឹងផ្តល់ជូនមេភូមិ អាជ្ញាធរឃុំ និងសហគមន៍មូលដ្ឋាន ដែលមានទីតាំងក្នុងគម្រោង។ គ្រួសារប៉ះពាល់ នឹងត្រូវបានពិគ្រោះដោយផ្ទាល់ តាមរយៈការប្រជុំពិគ្រោះយោបល់ជាសាធារណៈ ស្តីពីបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់ពួកគាត់។ ការប្រជុំពិគ្រោះយោបល់បែបនេះនឹងធ្វើឡើង (i) មុនពេលចាប់ផ្តើមធ្វើការអង្កេតវាស់វែងលម្អិត (ដើម្បីជូនដំណឹងពីកម្មវិធីអង្កេតវាស់វែង និងដំណើរការ), (ii) បន្ទាប់ពីការវាស់វែងលម្អិត (ដើម្បីជូនដំណឹងពីលទ្ធផលនៃការវាស់វែងលម្អិត និងវិធានការកាត់បន្ថយផលប៉ះពាល់នានា), (iii) ក្នុងអំឡុងពេលរៀបចំធ្វើបច្ចុប្បន្នភាពផែនការដោះស្រាយផលប៉ះពាល់ (ដើម្បីកំណត់វិធានការសមរម្យសម្រាប់កម្មវិធីស្តារជីវភាពឡើងវិញ, ជូនព័ត៌មានស្តីពីអត្រាសំណង និងប្រាក់ឧបត្ថម្ភផ្សេងៗ និងការរៀបចំលម្អិតអំពីការតាំងទីលំនៅឡើងវិញ); (iv) ការអនុវត្តផែនការសកម្មភាពដោះស្រាយផលប៉ះពាល់។ គម្រោងនឹងផ្សព្វផ្សាយជាសាធារណៈសៀវភៅផែនការដោះស្រាយផលប៉ះពាល់ដែលបានអនុម័តតាមរយៈកូនសៀវភៅព័ត៌មានសាធារណៈ (ដែលត្រូវចែកជូនដល់គ្រប់គ្រួសារប៉ះពាល់), តាមរយៈសៀវភៅផែនការដោះស្រាយផលប៉ះពាល់ដែលបានបកប្រែ ជូនទៅគ្រប់ការិយាល័យស្រុក ឃុំ ដើម្បីអាចអនុញ្ញាតិឲ្យគ្រប់គ្នាអាចអាន និង តាមរយៈការបង្ហោះនៅក្នុងគេហទំព័ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី។

## បើសិនខ្ញុំមិនយល់ព្រម ឬបញ្ហាកើតឡើងក្នុងពេលអនុវត្តគម្រោង ដូចជាសំណងបច្ចេកទេស និងបញ្ហានានាដែលកើតចេញពីគម្រោង តើខ្ញុំមានសិទ្ធិប្តឹងតវ៉ាដែរឬទេ?

ចំលើយ៖បាទ មាន។ បើប្រជាពលរដ្ឋរងផលប៉ះពាល់មានមន្ទិល ឬមិនពេញចិត្តចំពោះកញ្ចប់សំណងដែលផ្តល់ជូន ឬក៏ដោយហេតុផលណាមួយ សំណងមិនពិតដូចការព្រមព្រៀងប្រជាពលរដ្ឋរងផលប៉ះពាល់មានសិទ្ធិដាក់បណ្តឹងតវ៉ាបាន។ យន្តការដោះស្រាយបណ្តឹងតវ៉ាត្រូវដំណើរការជា ៤ ដំណាក់កាលដូចតទៅ៖

**កំណាក់កាលទីមួយ:** គ្រួសាររងផលប៉ះពាល់នឹងបង្ហាញបណ្តឹងតវ៉ា និងសាទុក្ខដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដល់ប្រធានភូមិ មេឃុំ ឬក្រុមការងារ ស់គណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ (IRC) និង ណៈកម្មការដោះស្រាយផលប៉ះពាល់ថ្នាក់ខេត្ត (PRSC-WG)។ បុគ្គលិកដែលទទួលពាក្យបណ្តឹង មានកាតព្វកិច្ចផ្តល់ភ្លាមនូវការអះអាងជាលាយលក្ខណ៍អក្សរពីការទទួលការតវ៉ានេះ។ បើក្រោយពី ១៥ ថ្ងៃមក គ្រួសាររងផលប៉ះពាល់ដែលតវ៉ាមិនបានឮដំណឹងអ្វីពីប្រធានភូមិ និងមេឃុំ ឬពីក្រុមការងារទេ ឬក៏បើគាត់មិនពេញចិត្តនឹងការសម្រេចចិត្តនៅដំណាក់កាលទីមួយនោះទេ បណ្តឹងតវ៉ាអាចត្រូវបានបញ្ជូនទៅមន្ទីរស្រុក ។ **ដំណាក់កាលទីពីរ:** មន្ទីរស្រុកមានពេល ១៥ ថ្ងៃសម្រាប់ដោះស្រាយការតវ៉ាឱ្យឈានដល់ការពេញចិត្តរបស់គ្រប់ភាគីពាក់ព័ន្ធ។ បើបណ្តឹងតវ៉ាមិនអាចដោះស្រាយបាននៅដំណាក់កាលនេះទេ មន្ទីរស្រុកនឹងនាំយកករណីនេះទៅគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាខេត្ត ។ **ដំណាក់កាលទីបី:** គណៈកម្មការដោះស្រាយបណ្តឹងតវ៉ាខេត្តជួបជាមួយភាគីតវ៉ា ហើយសាកល្បងដោះស្រាយ។ គណៈកម្មការអាចស្នើឱ្យមន្ត្រីតាមដានត្រួតពិនិត្យខាងក្រៅ (EMO) ពិនិត្យការអង្កេតវាស់វែងលម្អិត (DMS) ឡើងវិញ។ ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីដាក់ពាក្យបណ្តឹងតវ៉ាមក គណៈកម្មការត្រូវធ្វើការសម្រេចចិត្តជាលាយលក្ខណ៍អក្សរ ហើយបញ្ជូនច្បាប់ចម្លងទៅក្រសួងសាធារណការនិងដឹកជញ្ជូន (MPWT), (PDPWT), (EMO), (PRS), (IRC) និងគ្រួសាររងផលប៉ះពាល់។ **ដំណាក់កាលចុងក្រោយ:** ប្រសិនបើគ្រួសាររងផលប៉ះពាល់ដែលតវ៉ាមិនបានឮដំណឹងអ្វីពីគណៈកម្មការដោះស្រាយបណ្តឹងតវ៉ាខេត្ត ឬមិនពេញចិត្តទេនោះ គាត់អាចនាំយកករណីនេះទៅតុលាការខេត្ត។ នេះគឺជាដំណាក់ការចុងបញ្ចប់សម្រាប់ការវិនិច្ឆ័យបណ្តឹងតវ៉ានេះ។

## តើធ្វើយ៉ាងដូចម្តេចទើបយើងអាចដឹងថាកិច្ចការទាំងនេះបានអនុវត្ត ហើយសម្រេចបានគោលបំណងនៃគម្រោង?

រាល់សកម្មភាពនៃគម្រោងទាំងអស់ នឹងត្រូវបានត្រួតពិនិត្យដោយការិយាល័យបរិស្ថាន និងសង្គម របស់ក្រសួងសាធារណការនិងដឹកជញ្ជូន និងដោយភ្នាក់ងារត្រួតពិនិត្យខាងក្រៅ (EMA)។

### ព័ត៌មានបន្ថែម និងមតិយោបល់:

1. មន្ទីរសាធារណការនិងដឹកជញ្ជូន (PDPW), អនុគណៈកម្មការដោះស្រាយផលប៉ះពាល់ខេត្ត
2. អង្គភាពគ្រប់គ្រងគម្រោងទី៣, គម្រោងកែលម្អផ្លូវខេត្តៈ ជាន់ទី៤, ផ្លូវនរោត្តមកែងផ្លូវលេខ១០៦, ភ្នំពេញ (023 724565)
3. គណៈកម្មការអន្តរក្រសួង/ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (023 4266 82)
4. ធនាគារអភិវឌ្ឍន៍អាស៊ីៈ ភ្នំពេញ (023) 215 805

# ក្រសួងសាធារណការ និងដឹកជញ្ជូន

## គម្រោងកែលម្អផ្លូវខេត្តកម្ពុជាទី២

## កូនសៀវភៅព័ត៌មានសាធារណៈ



## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា ស្នើថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់ជំនួយបច្ចេកទេស ដើម្បីសិក្សាពីគម្រោងកែលម្អផ្លូវខេត្តលេខ៣១២ ក្នុងខេត្តព្រៃវែង, លេខ២៣ ក្នុងខេត្តកណ្តាល, និងលេខ១៥៣៤ ក្នុងខេត្តកំពង់ឆ្នាំងនិងពោធិ៍សាត់។

គោលបំណងនៃគម្រោងនេះ គឺជួយព្រះរាជាណាចក្រកម្ពុជា ក្នុងការធ្វើឲ្យជីវភាពប្រជាជនដែលរស់នៅតាមខេត្តព្រៃវែង កណ្តាល កំពង់ឆ្នាំង និងពោធិ៍សាត់មានជីវភាពប្រសើរឡើង តាមរយៈការផ្តល់ផ្លូវទៅកាន់ទីផ្សារ និងសេវាកម្មសំខាន់ៗដូចជាៈ ១. កម្មវិធីស្តារផ្លូវឡើងវិញ, ២. កម្មវិធីពង្រឹងសមត្ថភាព និងបណ្តុះបណ្តាល, និង ៣. ការរៀបចំយុទ្ធសាស្ត្រនិងគោលនយោបាយសាធារណៈដែលមានភាពប្រសើរ។

## តើយើងនឹងប៉ះពាល់ដោយសារគម្រោងទេ?

ក្រសួងសាធារណការ និងដឹកជញ្ជូន កំណត់របៀងនៃផលប៉ះពាល់ (COI) ដែលនាពេលនេះ ជាទូទៅគឺ ៨ម នៅទីប្រជុំជន និង១០ម នៅទីជនបទ ពីអ័ក្សកណ្តាល សង្ខាងផ្លូវ។ ក្រសួង នឹងវាស់និងវាយបង្គោលនៅលើដី មុននឹងចាប់ផ្តើមការងារវាស់វែងលម្អិត (DMS)។ គោលបំណងនៃការបោះបង្គោលនេះគឺ កំណត់តំបន់សម្រាប់ការកែលម្អផ្លូវ និងកំណត់ថាតើនរណាខ្លះនឹងប៉ះពាល់ដោយសារគម្រោងនេះ។

## តើគម្រោងត្រូវគិតយ៉ាងដូចម្តេចបើដីរបស់ខ្ញុំនឹងត្រូវប៉ះពាល់?

ដីឯកជនដែលប៉ះដោយសារគម្រោង នឹងទទួលបានសំណងតាមអត្រាតម្លៃទីផ្សារ ចំណែកឯដីដែលស្ថិតនៅក្នុងចំណីថ្នល់ នឹងមិនទទួលបានសំណងទេ។ ប៉ុន្តែ ចំពោះអ្នកដែលបាត់បង់ផលិតកម្ម (កសិកម្ម) នៅលើដីចំណីថ្នល់ នឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការមិនបានបន្តប្រើប្រាស់ដីផលិតកម្មនោះ។

## តើនរណាខ្លះនឹងមានសិទ្ធិទទួលបានសំណង?

ឱសានុវាទសម្រាប់សិទ្ធិទទួលបានប្រាក់សំណង និងប្រាក់ឧបត្ថម្ភផ្សេងៗ ត្រូវបានកំណត់សម្រាប់គម្រោងនិមួយៗ ដោយយោងទៅតាមការបរិច្ឆេទនៃការបញ្ចប់សារពើភ័ណ្ឌនៃទ្រព្យសម្បត្តិដែលបាត់បង់ ក្នុងនោះគឺ (១) ថ្ងៃទី ២៥ កក្កដា ២០១៦ សម្រាប់ផ្លូវខេត្តលេខ ៣១២, (២) ថ្ងៃទី ៤ សីហា ២០១៦ សម្រាប់ផ្លូវខេត្តលេខ២៣, និង (៣) ថ្ងៃទី២៨ សីហា ២០១៦ សម្រាប់ផ្លូវខេត្តលេខ១៥៣៤។

ចំពោះគ្រួសារប៉ះពាល់ដែលមានដី និងប្រើប្រាស់ដីមុនថ្ងៃឱសានុវាទ នឹងមានសិទ្ធិទទួលបានសំណង។ តែចំពោះជនដែលរំលោភ និងកាន់កាប់ដីក្រោយថ្ងៃឱសានុវាទ នឹងមិនមានសិទ្ធិទទួលសំណង ឬប្រាក់ឧបត្ថម្ភទេ។

## តើសំណងត្រូវផ្តល់ជូនចំពោះផ្ទះ ដើមឈើ និងដំណាំដែរឬទេ?

ប្រាកដណាស់ ផ្ទះ ដែលប៉ះពាល់ដោយសារគម្រោងនឹងត្រូវទទួលបានសំណងឧបត្ថម្ភគោលនយោបាយតាមអត្រាតម្លៃជំនួស ដោយមិនមានការកាត់ចេញនូវតម្លៃ ឬសំម្ភារៈដែលនៅសេសសល់ឡើយ។ ចំពោះផ្ទះដែលប៉ះតែផ្នែកណាមួយ នឹងទទួលបានសំណងសម្រាប់ការបាត់បង់ផ្នែកនោះ រួមនឹងថ្លៃជួសជុល។ រចនាសម្ព័ន្ធផ្សេងទៀត (ដូចជារបង, អណ្តូង, សាប) នឹងទទួលបានសំណងតាមអត្រាតម្លៃជំនួស។

ចំពោះដំណាំប្រចាំឆ្នាំ ការជូនដំណឹងជាមុននឹងត្រូវជូនទៅគ្រួសារប៉ះពាល់ ដើម្បីប្រមូលផលឲ្យបានទាន់ពេលវេលា។ ប្រសិនជាមិនអាចប្រមូលផលបាន គ្រួសារប៉ះពាល់ នឹងទទួលបានសំណងសំរាប់ការបាត់បង់ដំណាំតាមតម្លៃជំនួស។ ឯដើមឈើដែលប៉ះពាល់ នឹងទទួលបានសំណងតាមអត្រាតម្លៃជំនួស។

## ត្រូវគិតយ៉ាងដូចម្តេចចំពោះទ្រព្យសម្បត្តិសាធារណៈ?

អគារ និងរចនាសម្ព័ន្ធនានាដែលប៉ះពាល់ នឹងសាងសង់ឡើងវិញដូចរូបរាងដើម ឬក៏ល្អជាង។



## ករណីពាក់ព័ន្ធនឹងការផ្លាស់លំនៅដ្ឋាន ឬមុខរបរ តើគម្រោងនឹងជួយខ្ញុំយ៉ាងដូចម្តេចខ្លះ ក្នុងការសាងសង់ផ្ទះឡើងវិញអំឡុងពេលផ្លាស់ទីលំនៅ?

គ្រួសាររងផលប៉ះពាល់មានជម្រើសក្នុងការរំកិលថយក្រោយចេញពីរបៀងផលប៉ះពាល់ ប៉ុន្តែនៅតែស្ថិតក្នុងចំណីថ្នល់ ឬរំកិលចេញផុតពីចំណីថ្នល់។ ចំពោះអ្នករស់នៅក្នុងចំណីថ្នល់ នឹងអនុញ្ញាតិឲ្យបន្តការរស់នៅតទៅទៀត រហូតទាល់តែមានការចាំបាច់ពីរដ្ឋាភិបាលក្នុងការយកដីប្រើប្រាស់សម្រាប់ប្រយោជន៍សាធារណៈ ប៉ុន្តែមិនអនុញ្ញាតិឲ្យសង់សំណង់រឹងមាំទេ។ បើសិនជាមានតម្រូវការនាពេលអនាគតឲ្យផ្លាស់ប្តូរទីលំនៅ នោះទម្រង់នៃសំណងប្រហាក់ប្រហែលគ្នានឹងត្រូវបានផ្តល់ជូន។ អ្នកដែលរើទៅទីតាំងថ្មីក្នុងគម្រោងនេះ នឹងទទួលបានការឧបត្ថម្ភច្រើនជាង បើធៀបនឹងអ្នករំកិលថយក្រោយនៅក្នុងចំណីថ្នល់។

គ្រួសារដែលរងផលប៉ះពាល់នឹងទទួលបានប្រាក់សំណងតាមអត្រាតម្លៃជំនួសសម្រាប់ផ្ទះដែលរងផលប៉ះពាល់ រួមនឹងប្រាក់ឧបត្ថម្ភអំឡុងពេលអន្តរកាល ក្នុងដំណើរការផ្លាស់ទីតាំង។ ប្រាក់ឧបត្ថម្ភអន្តរកាលនេះមាន (i) ប្រាក់ឧបត្ថម្ភការដឹកជញ្ជូន;(ii) ទទួលបានប្រាក់ឧបត្ថម្ភម្តង ចំនួន១០០ដុល្លា បើសិនរំកិលផ្ទះថយក្រោយក្នុងចំណីថ្នល់ ឬ ២០០ដុល្លា បើសិនរំកិលចេញពីចំណីថ្នល់; (iii) ប្រាក់ឧបត្ថម្ភការរំខានមុខរបរ; និង(iv) ប្រាក់ឧបត្ថម្ភសម្រាប់គ្រួសារងាយរងគ្រោះ។ អ្នកជួលនឹងមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការជួលរយៈពេលពីរខែ។ ចំនួនពិតប្រាកដនៃអត្រាសំណង និងប្រាក់ឧបត្ថម្ភផ្សេងៗ នឹងជូនដំណឹងនៅពេលធ្វើបច្ចុប្បន្នភាពផែនការដោះស្រាយផលប៉ះពាល់។

## បើសិនប៉ះពាល់ដល់ជីវភាពរស់នៅ តើគម្រោងអាចជួយខ្ញុំយ៉ាងដូចម្តេចក្នុងការស្តារជីវភាពឡើងវិញ?

ស្ថិតិ និងការអង្កេតវាស់វែងលម្អិត (DMS) នឹងកត់ត្រាទុក ចំពោះជនដែលប៉ះពាល់ដល់ជីវភាពរស់នៅ និងការប៉ះពាល់ផ្សេងៗទៀតដែលអាចកើតចេញពីគម្រោង។

គម្រោងនឹងផ្តល់ជូនការឧបត្ថម្ភផ្សេងៗ ដើម្បីឲ្យជនប៉ះពាល់ទាំងឡាយអាចស្តារជីវភាពរស់នៅឡើងវិញ យ៉ាងហោចណាស់បានដូចមុនពេលគម្រោងទៅដល់។ ចំពោះគ្រួសារងាយរងគ្រោះ (ឧ.ជនដែលចាត់ទុកថាក្រីក្រ, ពិការ) គម្រោងនឹងខិតខំជួយកែលម្អជីវភាពរស់នៅ ឲ្យបានយ៉ាងហោចណាស់ត្រឹមកម្រិតមុនគម្រោងទៅដល់។ ទម្រង់នៃការឧបត្ថម្ភនេះ នឹងរួមមាន: (i) ការឧបត្ថម្ភម្តងចំពោះគ្រួសារដែលបាត់បង់ច្រើនជាង ១០% នៃដីផលិតកម្ម ឬតម្រូវឲ្យរំកិលផ្ទះឬហាងចេញពីរបៀងនៃផលប៉ះពាល់ ដោយអាស្រ័យលើប្រភេទ និងទំហំនៃផលប៉ះពាល់។; (ii) ចំពោះអ្នកបាត់បង់ដីផលិតកម្មក្នុងចំណីថ្នល់ នឹងទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ការបាត់បង់នៃការប្រើប្រាស់ដី; (iii) ប្រាក់ឧបត្ថម្ភសម្រាប់សោយហ៊ុយដឹកជញ្ជូន; (iv) ប្រាក់សម្រាប់ការរំខានបណ្តោះអាសន្ននៃចំណូលមុខរបរចំពោះហាង/តូបដែលប៉ះពាល់; (v) សក្តានុពលទម្រង់ដ៏ទៃទៀតនៃវិធានការស្តារប្រាក់ចំណូលឡើងវិញ ដែលនឹងត្រូវកំណត់ពេលធ្វើបច្ចុប្បន្នភាពផែនការដោះស្រាយផលប៉ះពាល់ ដោយមានការពិគ្រោះយោបល់ជាមួយជនប៉ះពាល់; និង (vi) មានការឧបត្ថម្ភបន្ថែមចំពោះគ្រួសារងាយរងគ្រោះ។

## អ្វីទៅជាការអង្កេតវាស់វែងលម្អិត ហើយពេលណានឹងចាប់ផ្តើម?

ការអង្កេតវាស់វែងលម្អិត គឺជាការអង្កេតលម្អិត ១០០% នៃទ្រព្យសម្បត្តិរបស់ជនរងប៉ះពាល់ទាំងអស់ ដើម្បីចងក្រងឯកសារនៃទ្រព្យសម្បត្តិប៉ះពាល់ទាំងនោះ មានដី ផ្ទះ ហាង រចនាសម្ព័ន្ធផ្សេងៗទៀត ដំណាំនិងឈើហូបផ្លែ។ រៀបចំបង្កើតបញ្ជីឈ្មោះនៃគ្រួសារប៉ះពាល់ ដែលមានសិទ្ធិទទួលបាន